ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

# មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ ពីប្រទេសឡាវ និងម៉ាឡេស៊ី

------------

១- ស្ថានឯកអគ្គរាជទូត**កម្ពុជា**ប្រចាំប្រទេសម៉ាឡេស៊ី បានរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ ០១ នាក់ ឈ្មោះ **អ.ល** អាយុ ២៣ឆ្នាំ មកពីខេត្តឧត្តរមានជ័យ បានទៅប្រទេសម៉ាឡេស៊ី តាំងពីថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ២០១៥ និងធ្វើការជាអ្នកបោសសំអាត។ ដោយធ្វើការលំបាក ពលការិនីរូបនេះបានទៅស្ថានទូតនៅថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០១៦ ស្នើសុំជួយទាមទារប្រាក់ខែដែលនៅសេសសល់ពីនិយោជក និងជួយឱ្យបានត្រឡប់មកកម្ពុជាវិញ។

ដោយមានកិច្ចអន្តរាគមន៍ពីស្ថានទូត និយោជក បានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសេសសល់ និងលិខិតឆ្លងដែនជូនពលការិនី **អ.ល** តាមសំណូមពររបស់ស្ថានទូត។

ពលការិនី **អ.ល** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី **៩** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង**០៩:៥០ ព្រឹក** តាមជើងយន្តហោះ MH754។ អំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគដល់ពលការិនីរូបនេះផងដែរ។

២- ស្ថានឯកអគ្គកុងស៊ុល**កម្ពុជា**ប្រចាំនៅទីក្រុងប៉ាក់សេ ប្រទេសឡាវ បានសម្របសម្រួលជាមួយអាជ្ញាធរឡាវ អន្តរាគមន៍ជួយដោះលែងពលរដ្ឋខ្មែរ០១នាក់ ឈ្មោះ **ឯ.ប.ល** ភេទប្រុស អាយុ ២៨ឆ្នាំ មកពីខេត្តព្រះវិហារ ដែលត្រូវបានអាជ្ញាធរឡាវឃុំខ្លួន នៅមន្ទីរឃុំឃាំងទីបញ្ជាការយោធាខេត្តចំប៉ាសាក់ កាលពីថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ពីបទឆ្លងដែនខុសច្បាប់ ប្រើប្រាស់លុយដុល្លាក្លែងក្លាយ និងចោរកម្ម ដើម្បីឱ្យបានវិលត្រឡប់មកកម្ពុជាវិញ។

ពលរដ្ឋខ្មែរខាងលើ បានវិលត្រឡប់មកដល់លំនៅឋានវិញហើយ កាលពី**ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦** ៕

ភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ